ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ១៧០៩ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំ ក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែ សីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានធនធានមនុស្ស ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៣០៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ
- យោងតាមការងារចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.**_

សេចក្តីសម្រេចនេះកំណត់អំពីការបែងចែក និងប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រី រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ ដើម្បីធានាការដឹកនាំប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

**ប្រការ២.**_

រដ្ឋមន្ត្រី ទទួលខុសត្រូវដឹកនាំការងាររួមរបស់ក្រសួងមហាផ្ទៃ ។

**ប្រការ៣._**

ត្រូវបានបែងចែកប្រគល់ភារកិច្ចជូនរដ្ឋលេខាធិការ ដើម្បីជួយរដ្ឋមន្ត្រី ដូចខាងក្រោម៖

១. ឯកឧត្តម សន្តិបណ្ឌិត **ម៉ៅ ច័ន្ទតារា** ជារដ្ឋលេខាធិការប្រចាំការ ទទួលជួយរដ្ឋមន្ត្រីលើការងារអគ្គលេខាធិការដ្ឋាន

២. ឯកឧត្តម សន្តិបណ្ឌិត **អ៊ុក គីមលេខ** ទទួលជួយរដ្ឋមន្ត្រី តាមការប្រគល់ភារកិច្ច

៣. ឯកឧត្តម **ម៉ាច ហាម ផាន** ទទួលជួយរដ្ឋមន្ត្រីលើការងារអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

៤. លោកជំទាវ **ជូ ប៊ុនអេង** ទទួលជួយរដ្ឋមន្ត្រីលើការងារប្រឆាំងការជួញដូរមនុស្ស

៥. ឯកឧត្តម សន្តិបណ្ឌិត **ខាន់ អ៊ាន** ទទួលជួយរដ្ឋមន្ត្រីលើការងារអគ្គនាយកដ្ឋានធនធានមនុស្ស

៦. ឯកឧត្តម សន្តិបណ្ឌិត **ខៀវ សុភ័គ** ទទួលបន្ទុកជានាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

៧. ឯកឧត្តម សន្តិបណ្ឌិត **សុខ ផល** ទទួលជួយរដ្ឋមន្ត្រីលើការងារផែនសន្តិសុខ

៨. ឯកឧត្តម **កៅ ខុនដារ៉ា** ទទួលជួយរដ្ឋមន្ត្រីលើការងារភស្តុភារ និងហិរញ្ញវត្ថុ ផ្នែករដ្ឋបាលទូទៅ នាយកដ្ឋានស្ថាបនា និងវិស្វកម្ម និងគណៈកម្មាធិការសម្របសម្រួល ជំរុញ អនុវត្ត និងត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន នៃក្រសួងមហាផ្ទៃ

៩. ឯកឧត្តម **ម៉ិន ហុន** ទទួលជួយរដ្ឋមន្ត្រីលើការងារក្រុមប្រឹក្សានីតិកម្ម និងល្បែងពាណិជ្ជកម្ម

១០. ឯកឧត្តម **ឌី សុភផាន** និងឯកឧត្តម **មៀច សុផាន់ណា** ទទួលជួយរដ្ឋមន្ត្រីលើការងារសមាគមអង្គការក្រៅរដ្ឋាភិបាល និងគណបក្សនយោបាយ

១១. ឯកឧត្តម **ឡឿន សុវណ្ណ** ទទួលជួយរដ្ឋមន្ត្រីលើការងារគណៈកម្មការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម

១២. ឯកឧត្តម **អេង មង្គល** ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គាធិការដ្ឋាន

១៣. ឯកឧត្តម **ស៊ីរិទ្ធ ឌី** និងឯកឧត្តម **ហ៊ុ សាគុណណ** ទទួលជួយរដ្ឋមន្ត្រីលើការងារផែននគរបាលព្រំដែន

១៤. ឯកឧត្តម **យុន ឈុន្នី** ទទួលជួយរដ្ឋមន្ត្រី លើការងារលេខាធិការដ្ឋានអនុវត្តគោលនយោបាយ «ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព» និងការងារប៉ុស្តិ៍នគរបាលរដ្ឋបាល

១៥. ឯកឧត្តម **កុល ច័រកេ្ស** ទទួលជួយរដ្ឋមន្ត្រី លើការងារបណ្តុះបណ្តាលមន្ត្រីរាជការរដ្ឋបាលស៊ីវិល និងសាលាជាតិរដ្ឋបាលមូលដ្ឋាន

១៦. ឯកឧត្តម **ស៊ាង ប៊ុនលាង** ទទួលជួយរដ្ឋមន្ត្រីលើការងារគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងមហាផ្ទៃ

១៧. ឯកឧត្តម **អ៊ុត សំអន** និងឯកឧត្តម **អ៊ុង សាមី** ទទួលជួយរដ្ឋមន្ត្រីលើការងារកិច្ចការរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់ និងក្រុមការងារអន្តរក្រសួងកាត់ឆ្កៀលដីពីតំបន់ការពារ

១៨. ឯកឧត្តម **ម៉ូន សារ៉ន** ទទួលជួយរដ្ឋមន្ត្រីលើការងារការពារសន្តិសុខនាយករដ្ឋមន្ត្រី

១៩. ឯកឧត្តម **អ៊ុំ ម៉ារ៉ា** និងឯកឧត្តម **ផាន់ ចាន់ធុល** ទទួលជួយរដ្ឋមន្ត្រីលើការងារកិច្ចការរដ្ឋបាល រាជធានី ខេត្ត ខណ្ឌ និងទទួលការងារជាមន្ត្រីជាន់ខ្ពស់ទំនាក់ទំនងកម្ពុជា-ឡាវ (SOM)

២០. ឯកឧត្តម **រស់ ចរុណ** ទទួលជួយរដ្ឋមន្ត្រីលើការងារអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

២១. ឯកឧត្តម **ជាច តាយ** ទទួលជួយរដ្ឋមន្ត្រីតាមការប្រគល់ភារកិច្ច

២២. ឯកឧត្តម **សួស អន្តារ៍** ទទួលជួយរដ្ឋមន្ត្រីលើការងារភេស្តុភារ និងហិរញ្ញវត្ថុ ផ្នែកសន្តិសុខសាធារណៈ

២៣. លោកជំទាវ **មឿង ស៊ាចសេច** ទទួលជួយរដ្ឋមន្ត្រីលើការងារគ្រប់គ្រង និងថែរក្សាទីស្តីការ ក្រសួងមហាផ្ទៃ

២៤. លោកជំទាវ **អុច សុភាច៍** ទទួលជួយរដ្ឋមន្ត្រីលើការងារយេនឌ័រក្រសួងមហាផ្ទៃ និងការងារគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍/កាមរោគនៃក្រសួងមហាផ្ទៃ

២៥. ឯកឧត្តម **រាជ សុគន្ធ** ទទួលជួយរដ្ឋមន្ត្រីលើការងារលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត

២៦. ឯកឧត្តម **ប្រាក់ សំអឿន** ទទួលជួយរដ្ឋមន្ត្រីលើការងារអគ្គនាយកដ្ឋានរដ្ឋបាល ការងារផ្ទេរមុខងារ និងធនធាន ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធការងារអភិវឌ្ឍន៍មូលដ្ឋាន ការងារទីក្រុងឆ្លាត (ASCN) ការងារជាមន្ត្រីជាន់ខ្ពស់ទំនាក់ទំនងកម្ពុជា-ថៃ(SOM) និងកម្ពុជា-វៀតណាម(SOM) ការងារការិយាល័យ/យន្តការច្រកចេញចូលតែមួយ ការងារកំណែទម្រង់អភិបាលកិច្ច និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ

២៧. ឯកឧត្តម **ជា សុគន្ធា** ទទួលជួយរដ្ឋមន្ត្រីលើការងារតាមដានការដោះស្រាយ សំណើ សំណូមពររបស់មហាជនក្នុងទំព័រហ្វេសប៊ុក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងហ្វេសប៊ុកសម្តេចក្រឡាហោម និងក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាស្រាវជ្រាវ និងដោះស្រាយករណីរកឃើញគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះក្នុងនាវាដែលលិចក្នុងទន្លេ សមុទ្រ

២៨. ឯកឧត្តម **សរ សិទ្ធិ** ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកីឡា ក្រសួងមហាផ្ទៃ

២៩. ឯកឧត្តម **ឌុច ណារ៉ុថ** ទទួលជួយរដ្ឋមន្ត្រីលើការងារការពារគោលដៅព្រះបរមរាជវាំង និងព្រះមហាក្សត្រ

៣០. ឯកឧត្តម **គង់ សុខន** ទទួលជួយរដ្ឋមន្ត្រីលើការងារផែននគរបាលយុត្តិធម៌

៣១. ឯកឧត្តម សន្តិបណ្ឌិត **គៀត ច័ន្ទថារិទ្ធ** ទទួលជួយរដ្ឋមន្ត្រីលើការងារអគ្គនាយកដ្ឋានអន្តោប្រវេសន៍

៣២. ឯកឧត្តម **នែម សាខុន** ទទួលជួយរដ្ឋមន្ត្រីលើការងារអគ្គនាយកដ្ឋានពន្ធនាគារ

៣៣. ឯកឧត្តម **ហ៊ឹម យ៉ាន** និង ឯកឧត្តម **ម៉ក់ ជីតូ** ទទួលជួយរដ្ឋមន្ត្រីលើការងារផែនសណ្តាប់ធ្នាប់សាធារណៈ និងការងារចរាចរណ៍

៣៤. ឯកឧត្តម **ជាំ ឌុទ្ធី** ទទួលជួយរដ្ឋមន្ត្រីលើការងារជ្រើសរើស និងចាត់បញ្ជូនមន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារទៅបំពេញបេសកកម្មថែរក្សាសន្តិភាពក្រោមឆ័ត្រអង្គការសហប្រជាជាតិ

៣៥. ឯកឧត្តម **ឆោ តក្តិ** ទទួលជួយរដ្ឋមន្ត្រីលើការងារអគ្គនាយកដ្ឋានបច្ចេកវិទ្យាទីជីថល និងផ្សព្វផ្សាយអប់រំ ការងារ SOMTC-AMMTC ការងារ ASEAN ការងារទំនាក់ទំនងអន្តរជាតិទ្វេភាគី ឬពហុភាគី និងការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

៣៦. ឯកឧត្តម **ខៀវ តារិទ្ធ** ទទួលជួយរដ្ឋមន្ត្រីលើការងារគណៈបញ្ជាការដឹកនាំអនុវត្តផែនការយុទ្ធសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ដោយសារសំណល់ជាតិផ្ទុះពីសង្គ្រាមរបស់កងកម្លាំងនគរបាលជាតិ

៣៧. ឯកឧត្តម **ចាន់ សុធា** ទទួលជួយរដ្ឋមន្ត្រីលើការងារលេខាធិការដ្ឋាន គ.ជ.អ.ប

៣៨. ឯកឧត្តម **នៅ លក្ខណា** ទទួលជួយរដ្ឋមន្ត្រីលើការងារCLV មេគង្គ-ឡានចាង និងការងារគណៈកម្មការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម

៣៩. ឯកឧត្តម **នុច ចិសាលសុខ** ទទួលជួយរដ្ឋមន្ត្រីលើការងារបណ្ឌិត្យសភានគរបាលកម្ពុជា និងសាលាជាតិរដ្ឋបាលមូលដ្ឋាន។

**ប្រការ៤._**

ត្រូវបានបែងចែកប្រគល់ភារកិច្ចជូនអនុរដ្ឋលេខាធិការ ដូចខាងក្រោម៖

១. ឯកឧត្តម **អ៊ុំ ចន្ទណ្ណា** ទទួលបន្ទុកជានាយករងប្រចាំការ នៃខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២. ឯកឧត្តម **ឆោ ចន្ទណ្ណាត** ទទួលកិច្ចការងារការពារសន្តិសុខរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

៣. ឯកឧត្តម **អ៊ុច សុខុន** ទទួលជួយរដ្ឋមន្ត្រីលើការងារការពារសន្តិសុខសណ្តាប់ធ្នាប់ទីស្តីការក្រសួងមហាផ្ទៃ

៤. ឯកឧត្តម **អ៊ុច ចាន់ណារ៉ា** ទទួលជួយពិនិត្យឯកសារច្បាប់ពាក់ព័ន្ធការងារហិរញ្ញប្បទានភេរវកម្មអាវុធមហាប្រល័យ ការងារទំនាក់ទំនងអន្តរជាតិ ទ្វេភាគី ឬពហុភាគី និងជួយកិច្ចការឯកឧត្តមសន្តិបណ្ឌិត **សុខ ផល** រដ្ឋលេខាធិការ

៥. លោកជំទាវ **នុច ដាណា** ជួយកិច្ចការងាររដ្ឋមន្ត្រី និងជួយកិច្ចការងារឯកឧត្តម សន្តិបណ្ឌិត **គៀត ច័ន្ទថារិទ្ធ** រដ្ឋលេខាធិការ

៦. ឯកឧត្តម **ប៉ុលី ដា** និងឯកឧត្តម **ទ្រី សុខហេង** ជួយកិច្ចការងារឯកឧត្តម សន្តិបណ្ឌិត **ម៉ៅ ច័ន្ទតារា** រដ្ឋលេខាធិការប្រចាំការ

៧. ឯកឧត្តម សន្តិបណ្ឌិត **ចាន់ គីមសេង** និងឯកឧត្តម **ម៉ៅ សំបុណ្ណ** ជួយកិច្ចការងារឯកឧត្តម **ម៉ាច ចាម ដាន** រដ្ឋលេខាធិការ

៨. លោកជំទាវ **ជួញ សុផែ** និងលោកជំទាវ **គង់ ស៊ីផា** ជួយកិច្ចការងារលោកជំទាវ **ជួ ប៊ុនអេង** រដ្ឋលេខាធិការ

៩. ឯកឧត្តម **ហ៊ិន សុធី** និងឯកឧត្តម **សុខ ច័ន្ទរិទ្ធី** ជួយកិច្ចការងារឯកឧត្តម សន្តិបណ្ឌិត **ចាន់ ស៊ាន** រដ្ឋលេខាធិការ ។.

១០. ឯកឧត្តម **គី ដារ៉ា** ឯកឧត្តម **ម៉ុម សារឿន** និងឯកឧត្តម **ឈឹម សេរីតួន** ជួយកិច្ចការងារ ឯកឧត្តម សន្តិបណ្ឌិត **ខៀវ សុភ័គ** រដ្ឋលេខាធិការ

១១. ឯកឧត្តម **កែច ចណ្ណថន** ជួយកិច្ចការងារឯកឧត្តម សន្តិបណ្ឌិត **សុខ ផល** រដ្ឋលេខាធិការ

១២. ឯកឧត្តម **ស្រ៊ុន លិញ** ជួយកិច្ចការងារឯកឧត្តម **កៅ ខុនដារ៉ា** រដ្ឋលេខាធិការ

១៣. ឯកឧត្តម **ផុន ម៉ិនថាល់** និងឯកឧត្តម **គង់ ប៊ូរ៉ា** ជួយកិច្ចការងារឯកឧត្តម **ម៉ិន ហុន** រដ្ឋលេខាធិការ

១៤. ឯកឧត្តម **ឡុង ផល** និងឯកឧត្តម **រស់ សាផល** ជួយកិច្ចការងារឯកឧត្តម **ឌី សុភផាន** រដ្ឋលេខាធិការ និងឯកឧត្តម **មៀច សុផាន់ណា** រដ្ឋលេខាធិការ

១៥. ឯកឧត្តម **សោម ច័ន្ទមីណា** និងលោកជំទាវ **ទី សាឌី** ជួយកិច្ចការងារឯកឧត្តម **ឡឿន សុវណ្ណ** រដ្ឋលេខាធិការ និងឯកឧត្តម **នៅ លក្ខណា** រដ្ឋលេខាធិការ

១៦. ឯកឧត្តម **ឈីម សុផា** ជួយកិច្ចការងារឯកឧត្តម **អង មង្គល** រដ្ឋលេខាធិការ

១៧. ឯកឧត្តម **សុខ មុនី** ឯកឧត្តម **គេង សួន** ឯកឧត្តម **ចាន់ ស៊ីថា** ឯកឧត្តម **ហុក ឈីន** និង ឯកឧត្តម **យិន ចំណាន** ជួយកិច្ចការងារឯកឧត្តម **សិរិទ្ធ ឌី** រដ្ឋលេខាធិការ និងឯកឧត្តម **ហ៊ុ សាគុណ** រដ្ឋលេខាធិការ

១៨. ឯកឧត្តម **លី គីមឡុង** ជួយកិច្ចការងារឯកឧត្តម **យុន ឈុន្នី** រដ្ឋលេខាធិការ

១៩. ឯកឧត្តម **គាង សេង** និងឯកឧត្តម **ហាស់ សុបិន** ជួយកិច្ចការងារឯកឧត្តម **គុល ចរិក្ស** រដ្ឋលេខាធិការ និងឯកឧត្តម **នុច ចរិសាលសុខ** រដ្ឋលេខាធិការ

២០. ឯកឧត្តម **អ៊ុច លាង** ជួយកិច្ចការងារឯកឧត្តម **អ៊ុត សំអន** រដ្ឋលេខាធិការ និងឯកឧត្តម **អ៊ុង សាមី** រដ្ឋលេខាធិការ

២១. ឯកឧត្តម **ពីម សំណាង** ឯកឧត្តម **អៀង ចន្ថា** និងឯកឧត្តម **អៀង អុនធី** ជួយកិច្ចការងារឯកឧត្តម **អ៊ី ម៉ារ៉ា** រដ្ឋលេខាធិការ និងឯកឧត្តម **ផាន់ ចាន់ធុល** រដ្ឋលេខាធិការ

២២. ឯកឧត្តម **ឯម សំណាង** និងឯកឧត្តម **ម៉ក់ សម្បត្តិ** ជួយកិច្ចការងារឯកឧត្តម **រស់ ចរុណ** រដ្ឋលេខាធិការ

២៣. ឯកឧត្តម **សុខ សារីវុធ** ជួយកិច្ចការងារឯកឧត្តម **សួស អង្គារ៍** រដ្ឋលេខាធិការ

២៤. លោកជំទាវ **ឆៀ តារាសាត** ជួយកិច្ចការងារលោកជំទាវ **ម៉ឿង ស៊ាងសេង** រដ្ឋលេខាធិការ

២៥. លោកជំទាវ **ព្រំ ចន្ថា** ជួយកិច្ចការងារលោកជំទាវ **អុង សុភាច** រដ្ឋលេខាធិការ

២៦. ឯកឧត្តម សន្តិបណ្ឌិត **លូ រ៉ាមីន** ឯកឧត្តម **ឡាយ ណាវុធ** និងឯកឧត្តម **ហេង ពិន្ទុ** ជួយកិច្ចការងារឯកឧត្តម **ប្រាក់ សំអឿន** រដ្ឋលេខាធិការ

២៧. ឯកឧត្តម **បេ ធារឡុង** ជួយកិច្ចការងារឯកឧត្តម **ជា សុគន្ធា** រដ្ឋលេខាធិការ

២៨. ឯកឧត្តម **អាត់ ខែម** និងឯកឧត្តម **អ៊ុន ប៊ូរ៉ា** ជួយកិច្ចការងារឯកឧត្តម **អង សុខន** រដ្ឋលេខាធិការ

២៩. ឯកឧត្តម **ផាង ពៅ** និង ឯកឧត្តម **ហែម ថេង** ជួយកិច្ចការងារឯកឧត្តម សន្តិបណ្ឌិត **សៀក ចន្ទថារិទ្ធ** រដ្ឋលេខាធិការ

៣០. ឯកឧត្តម សន្តិបណ្ឌិត **ហេង ហាក់** ឯកឧត្តម **ហ៊ុយ ហឿន** លោកជំទាវ **សុខ សម្បត្តិ** និងឯកឧត្តម **អ៊ួន សុទ្ធា** ជួយកិច្ចការងារឯកឧត្តម **ឆែម សាខុន** រដ្ឋលេខាធិការ

៣១. ឯកឧត្តម **សេក តុម៉ី** និងឯកឧត្តម **សួន ឈាងលី** ជួយកិច្ចការងារឯកឧត្តម **ហ៊ឹម យ៉ាន** រដ្ឋលេខាធិការ និងឯកឧត្តម **ម៉ក់ ជីតូ** រដ្ឋលេខាធិការ

៣២. ឯកឧត្តម **អេង ឧត្តិ** ជួយកិច្ចការងារឯកឧត្តម **ម៉េង គគ្គី** រដ្ឋលេខាធិការ។

**ប្រការ៥._**

ក្រៅពីភារកិច្ចដូចបានចែងខាងលើ រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការគ្រប់រូបត្រូវបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រី ។

**ប្រការ៦._**

រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មានមន្ត្រីជំនួយការ ដែលតែងតាំងដោយប្រកាសរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមបទប្បញ្ញត្តិជាធរមាន ។

**ប្រការ៧._**

សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨._**

រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នាយកសាលាជាតិរដ្ឋបាលមូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែ ចេត្រ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

-ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-ដូចប្រការ៨

-ឯកសារ-កាលប្បវត្តិ